*រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០*

# សេចក្តីថ្លែងការណ៍រួម

## រយៈពេល៤ឆ្នាំកន្លងទៅហើយ ពុំទាន់មានការស៊ើបអង្កេតដោយប្រសិទ្ធភាពក្នុងករណីឃាតកម្មលើលោកបណ្ឌិត កែម ឡី

*ត្រូវបង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យ ដោយមានការចូលរួមពីអង្គការសហប្រជាជាតិ*

នៅថ្ងៃគម្រប់ខួប ៤ ឆ្នាំ នៃឃាតកម្មលើលោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយនិងអ្នកការពារសិទ្ធិមនុស្ស ដែលមានកិត្តិនាមនេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិលចំនួន ៣០ ដែលមានរាយនាមខាងក្រោម សូមអំពាវនាវឱ្យអាជ្ញាធរកម្ពុជាបង្កើតគណៈកម្មការស៊ើបអង្កេតដោយឯករាជ្យ និងឥតលម្អៀងមួយដើម្បីស៊ើបអង្កេតដោយប្រសិទ្ធភាព និងអាចជឿទុកចិត្តបាន នៅក្នុងករណីឃាតកម្មលើលោកបណ្ឌិត កែម ឡី ដែលអូសបន្លាយពេលយូរទៅហើយ។ យើងខ្ញុំក៏ស្នើដល់អាជ្ញាធរសូមបញ្ឈប់ការធ្វើទុក្ខបុកម្នេញ និងការឃាយឃីទៅលើបុគ្គលនានាដែលគោរពវិញ្ញាណក្ខន្ធរបស់លោកដោយសន្តិវិធី។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកបណ្ឌិត កែម ឡី ត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់ខណៈលោកកំពុងចូលរួមពិសារកាហ្វេក្នុងស្ថានីយប្រេងឥន្ធនៈមួយនៅកណ្តាលរាជធានីភ្នំពេញ។ ដោយពុំមានធ្វើការស៊ើបអង្កេតជាបន្ទាន់ ហ្មត់ចត់និងដោយឯករាជ្យ អាជ្ញាធរបានចាប់ខ្លួនបុរសម្នាក់ឈ្មោះ អឿត អាង ដែលបង្ហាញឈ្មោះខ្លួនឯងថា "ជួបសម្លាប់" និង "សារភាព" ថា ខ្លួនជាអ្នកសម្លាប់លោកបណ្ឌិត កែម ឡី ។ បន្ទាប់ពីការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ជាការជំនុំជម្រះដែលរងការរិះគន់យ៉ាងច្រើនដោយសារពុំស្របជាមួយបទដ្ឋានជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិនោះ តុលាការបានរកឃើញថាលោក អឿត អាង មានពិរុទ្ធភាពពីបទឃាតកម្ម និងបានផ្តន្ទាទោសគាត់ដាក់ពន្ធនាគារអស់មួយជីវិត។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ តុលាការកំពូលបានតម្កល់សាលក្រមកាត់ទោសនេះ។

ចាប់តាំងពីឆ្នាំ២០១៦ អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិជាច្រើនបានអំពាវនាវជាបន្តបន្ទាប់ឱ្យរដ្ឋាភិបាលកម្ពុជាបង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យមួយដើម្បីធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយមិនលម្អៀង និងមានប្រសិទ្ធភាពនៅក្នុងករណីឃាតកម្មនោះ ដោយមានគូសបញ្ជាក់ទាក់ទងនឹងការពិនិត្យលើជនដែលមានចំណែកត្រូវទទួលខុសត្រូវក្នុងបទល្មើសព្រហ្មទណ្ឌដទៃផ្សេងទៀតក្រៅពីជនដៃដល់ ស្របតាមបទដ្ឋានអន្តរជាតិដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(ក.អ.ស.ព.ន)។ គោលការណ៍នៃអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ដោយប្រសិទ្ធភាពលើការសម្លាប់ក្រៅប្រព័ន្ធច្បាប់ ដោយបំពាន និងដោយឆាប់រហ័ស ក៏ដូចជាពិធីសារបន្ថែមរដ្ឋមីនីសូតាស្តីពីការស៊ើបអង្កេតលើការស្លាប់ក្រៅច្បាប់ បានគូសបញ្ជាក់យ៉ាងច្បាស់ដល់តួនាទីរបស់រដ្ឋាភិបាលក្នុងការស៊ើបអង្កេតការស្លាប់ក្រៅច្បាប់នានា ព្រមទាំងអោយបង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យនៅពេលដែលរដ្ឋនានា ដូចជាប្រទេសកម្ពុជាជាដើម ដែលបញ្ហានីតិវិធីប្រកបដោយប្រសិទ្ធភាពក្នុងការស៊ើបអង្កេតអនុលោមតាមបទដ្ឋានអន្តរជាតិនៅមានកម្រិតនោះ។

រហូតមកទល់នឹងពេលនេះ រដ្ឋាភិបាលកម្ពុជាពុំបានចាត់វិធានការណាមួយក្នុងការបង្កើតគណៈកម្មការស៊ើបអង្កេតនោះទេ ដូចជាស្ថាប័នស៊ើបអង្កេតដោយឯករាជ្យ និងឥតលម្អៀងជាដើមនោះ។ ដោយសារកង្វះឆន្ទៈរបស់រដ្ឋា

ភិបាលក្នុងការស៊ើបអង្កេតដោយឯករាជ្យក្នុងករណីឃាតកម្មលើលោកបណ្ឌិត កែម ឡី និងកង្វះទំនុកចិត្តពីសំណាក់សង្គមស៊ីវិលលើប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា  គណៈកម្មការនោះគួរតែត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីសំណាក់អង្គការសហប្រជាជាតិនិងមានការចូលរួមពីអ្នកជំនាញឯករាជ្យ។

ការបន្តមានវិសមានចិត្តរបស់រដ្ឋាភិបាលចំពោះករណីរបស់លោកបណ្ឌិត កែម ឡី នេះ បង្កើននូវវិមតិសង្ស័យថាការធ្វើឃាតលោកនោះគឺជាការសងសឹក  ដោយសារលោកបំពេញការងារជាអ្នកការពារសិទ្ធិមនុស្ស។  លោកបណ្ឌិត កែម ឡី បានធ្វើការវិភាគបញ្ហាទាក់ទងនឹងសង្គមនិងនយោបាយជារឿយៗ។ លោកត្រូវបានឃាតករសម្លាប់បន្ទាប់ពីលោកបានផ្តល់សម្ភាសក្នុងកម្មវិធីវិទ្យុមួយអំពីរបាយការណ៍បែបស៊ើបអង្កេតទាក់ទងនឹងការក្តោបក្តាប់សេដ្ឋកិច្ចនៃខ្សែស្រឡាយអភិជន ដែលចេញផ្សាយដោយអង្គការអន្តរជាតិមួយឈ្មោះ ក្លូប៊ល វីតណេស  ដែលបរិយាយពិស្តារអំពីអំពើពុករលួយដ៏រីកសុះសាយនៅកម្ពុជា ដោយមានភ្ជាប់លោកនាយករដ្ឋមន្ត្រី ហើយនិងក្រុមគ្រួសាររបស់លោកផងដែរ។

រយៈពេលខ្លីបន្ទាប់ពីមរណៈភាពរូបលោក ភរិយារបស់លោក បណ្ឌិត កែមឡី ដែលនៅពេលនោះមានគភ៌ និងកូនប្រុសបួននាក់បានភៀសខ្លួនចេញពីប្រទេសកម្ពុជាដោយបារម្ភអំពីសុវត្ថិភាពដល់អាយុជីវិត។  ទីបំផុតប្រទេសអូស្ត្រាលីបានផ្តល់សិទ្ធិរស់នៅដល់ពួកគាត់បន្ទាប់ពីរងការគំរាមកំហែងជាច្រើនដល់ជីវិត  ខណៈពួកគាត់រស់នៅដោយលាក់បាំងអស់រយៈពេលជាងមួយឆ្នាំនៅប្រទេសថៃ។

បន្ទាប់ពីឃាតកម្មលើលោកបណ្ឌិត កែម ឡី អាជ្ញាធរកម្ពុជា បានបន្តឃ្លាំមើល យាយី រារាំង ការរៀបចំពិធីរំឭកខួបនៃមរណៈភាពរបស់លោកទៀតផង។ ជាងនេះទៀត អាជ្ញាធរបានបង្ខិតបង្ខំអោយបុគ្គលនានាដែលពាក់អាវមានសម្រង់សម្ដី ឬរូបភាពរបស់លោកបណ្ឌិត កែម ឡី ដោះចេញពីខ្លួន ឬបិទបាំងលើអាវនោះ។ ទង្វើទាំងនេះគឺជាការរឹតត្បិតដោយបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ  និងការជួបប្រជុំដោយសន្តិវិធី។  យើងខ្ញុំយល់ឃើញថាទង្វើទាំងនេះគឺជាការបំបិទសេរីភាពក្នុងការបញ្ចេញមតិ និងសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាបញ្ឈប់ការយាយីនេះ។

នៅខែកក្កដា ឆ្នាំ២០១៩ រយៈពេល១ថ្ងៃនៅមុនថ្ងៃគម្រប់ខួប ៣ ឆ្នាំ នៃមរណៈភាពរបស់លោកបណ្ឌិត កែម ឡី  អាជ្ញាធរបានចាប់ខ្លួនសកម្មជនយុវជន  គង់  រ៉ៃយ៉ា  ព្រមទាំងសមាជិកគ្រួសាររបស់លោកចំនួន៣នាក់ដោយសារការលក់អាវយឺតដែលមានរូបភាព និងសម្រង់សម្ដីដ៏ល្បីល្បាញរបស់លោកបណ្ឌិតកែម ឡី ចំនួនពីរ គឺ « *ជូតទឹកភ្នែករបស់អ្នក រួចបន្តដំណើរទៅមុខទៀត*» និង «*បើទោះជាអ្នកមិនធ្វើអ្វីសោះ ក៏អ្នកគង់រងគ្រោះ គ្រាន់តែពុំទាន់ដល់វេនអ្នកប៉ុណ្ណោះ*»។  តែយ៉ាងណាក្តី  នគរបាលបានដោះលែងសមាជិកគ្រួសាររបស់លោកដោយពុំមានការចោទប្រកាន់នោះទេបន្ទាប់ពីពួកគេបានចុះហត្ថលេខា  "សន្យា"  ថាពួកគេនឹងបញ្ឈប់សកម្មភាពតវ៉ាបែបនេះទៀតនៅពេលអនាគត  រីឯយុវជនរ៉ៃយ៉ា  នៅបន្តជាប់ឃុំបណ្ដោះអាសន្នក្រោមការចោទប្រកាន់ពីបទញុះញង់ដែលមានហេតុផលនយោបាយអស់រយៈពេលជិតប្រាំខែ  រហូតដល់ថ្ងៃអាជ្ញាធរដោះលែងលោកឱ្យនៅក្រៅឃុំនៅថ្ងៃទី២៨  ខែវិច្ឆិកា  ឆ្នាំ២០១៩។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ សាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់ គង់ រ៉ៃយ៉ា ដោយកំបាំងមុខពីបទ " ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្រោមមាត្រា ៨៨ មាត្រា ៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងកាត់ទោសដាក់ពន្ធនាគាររយៈពេល២ឆ្នាំ  ដោយទោសដែលនៅសល់របស់លោកត្រូវបានព្យួរដោយសារបានអនុវត្តទោសនៅពេលស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ លោក គង់ រ៉ៃយ៉ា ធ្លាប់ត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈ

ពេល១៨ ខែ ក្នុងឆ្នាំ២០១៥ ក្រោមការចោទប្រកាន់ពីបទញុះញង់ដែលពុំផ្អែកលើអង្គហេតុច្បាស់លាស់ទាក់ទងនឹងការបង្ហោះសារលើបណ្ដាញហ្វេសប៊ុករិះគន់រដ្ឋាភិបាល។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ អាជ្ញាធរបានចាប់ខ្លួនសកម្មជននិស្សិតម្នាក់ទៀតឈ្មោះ សួង នាគព័ន្ធ ដោយសារកាន់បដាមួយសរសេរថា " *បញ្ឈប់ការសម្លាប់ក្រៅច្បាប់* " នៅក្បែរស្ថានីយប្រេងឥន្ធនៈទីដែលលោកបណ្ឌិត កែម ឡី ត្រូវឃាតករសម្លាប់។ អាជ្ញាធរបានចោទប្រកាន់យុវនិស្សិតរូបនោះពីបទញុះញង់ និងឃុំខ្លួនលោកជាបណ្ដោះអាសន្ន ហើយលោកបន្តស្ថិតក្នុងការឃុំឃាំងរហូតដល់ថ្ងៃទទួលបានការដោះលែងឱ្យនៅក្រៅឃុំក្នុងខែវិច្ឆិកា ឆ្នាំ២០១៩។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសដោយកំបាំងមុខពីបទ "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្រោមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងកាត់ទោសលោកដាក់ពន្ធនាគាររយៈពេល២ឆ្នាំ លោកពុំធ្លាប់ត្រូវបានចាប់ខ្លួនឡើងវិញនៅឡើយ។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ អាជ្ញាធរបានចាប់ខ្លួនយុវជនជាបងប្អូនភ្លោះពីរនាក់ ឈ្មោះ ជុំ ហួត និងជុំ ហួរ ដោយសារប៉ុនប៉ងយកបាច់ផ្កាទៅតម្កល់នៅស្ថានីយប្រេងឥន្ធនៈនោះដូចគ្នា។ អាជ្ញាធរបានដោះលែងយុវជនទាំងពីរនាក់នោះវិញនៅថ្ងៃដដែល។

នៅមុនថ្ងៃគម្រប់ខួប៤ឆ្នាំនៃមរណៈភាពរបស់លោកបណ្ឌិត កែម ឡី អាជ្ញាធរបានចាប់ផ្តើមមានវិធានការរឹតត្បិតដើម្បីទប់ស្កាត់ ការគោរពវិញ្ញាណក្ខន្ធរបស់លោកដោយសន្តិវិធី។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ នគរបាលបានរារាំងយុវជនមួយក្រុម ក្នុងនោះមានទាំងព្រះសង្ឃផងក្នុងការរៀបចំពិធីបង្សុកូលដើម្បីឧទ្ទិសកុសលជូនលោកបណ្ឌិតតាមទំនៀមទម្លាប់នៃព្រះពុទ្ធសាសនានៅស្ថានីយប្រេងឥន្ធនៈទីដែលលោកបណ្ឌិតត្រូវបានធ្វើឃាត ។ អាជ្ញាធរបានឃាត់ខ្លួនម្នាក់ក្នុងចំណោមអ្នកទាំងនោះដែលពាក់អាវយឺតដែលមានបង្ហាញមុខរបស់លោកបណ្ឌិត កែម ឡី ដើម្បីសាកសួរ។ អាជ្ញាធរបានដោះលែងគាត់វិញបន្ទាប់ពីបានចុះកិច្ចសន្យាលើលិខិតមួយច្បាប់។

ការងាររបស់លោកបណ្ឌិត កែម ឡី ហើយនិងជីវិតរបស់លោកជានិមិត្តរូបនៃការគោរពសិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម។ លោកបានគូសបញ្ជាក់យ៉ាងច្បាស់ពីសារៈសំខាន់នៃការចូលរួមដោយស្មើភាព និងដោយសេរីរបស់ប្រជាពលរដ្ឋក្នុងនយោបាយ ហើយជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការចងក្រងបណ្ដាញ ការបញ្ចេញមតិ ការទទួលបានព័ត៌មាន និងការជួបប្រជុំជាសាធារណៈដោយសន្តិវិធី។ ការបន្តការយាយីរបស់រដ្ឋាភិបាលកម្ពុជាទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជនការងារ ព្រះសង្ឃ អ្នកសារព័ត៌មាន សមាជិកនៃគណបក្សជំទាស់ និងអ្នករិះគន់រដ្ឋាភិបាល ឆ្លុះបញ្ចាំងនូវវប្បធម៌និទណ្ឌភាពជាលក្ខណៈប្រព័ន្ធដែលការពារជនដែលមានចំណែកទទួលខុសត្រូវចំពោះការស្លាប់របស់លោកបណ្ឌិត កែម ឡី និងជាការបង្ក្រាបលើការបញ្ចេញមតិ ឬព័ត៌មានដែលរិះគន់លើរដ្ឋាភិបាលទៅវិញ។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលចំនួន ៣០ដែលមានរាយនាមខាងក្រោម នឹងនៅតែបន្តការអំពាវនាវអោយមានការស៊ើបអង្កេតដោយឯករាជ្យ ឥតលម្អៀង មានប្រសិទ្ធភាព និងហ្មត់ចត់ក្នុងករណីឃាតកម្មលើលោកបណ្ឌិតកែម ឡី ហូតទាល់តែជនទាំងឡាយដែលមានចំណែកទទួលខុសត្រូវចំពោះឃាតកម្មលើលោកត្រូវបាននាំខ្លួនមកផ្តន្ទាទោស ។

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ មានរាយនាមដូចខាងក្រោម៖**

១ អង្គការលើកលែងទោសអន្តរជាតិ

២ អង្គការមាត្រា១៩
៣ អាស៊ាន សមាជិកសភាដើម្បីសិទ្ធិមនុស្
៤ បណ្តាញប្រជាធិបតេយ្យអាស៊ី
៥ វេទិកាអាស៊ីសម្រាប់សិទ្ធិមនុស្សនិងការអភិវឌ្
៦ បណ្តាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី
៧ សម្ព័ន្ធសហជីពកម្ពុជា
៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
៩ សហព័ន្ធសហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា
១០ សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា
១១ វិទ្យាស្ថានកម្ពុជាដើម្បីប្រជាធិបតេយ្យ
១២ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស
១៣ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស
១៤ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ
១៥ អ្នកការពារសិទ្ធិស៊ីវិល
១៦ សម្ព័ន្ធសហគមន៍កសិករកម្ពុជា
១៧ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា
១៨ អង្គការ សមធម៌កម្ពុជា
១៩ អង្គការឃ្លាំមើលសិទ្ធិមនុស្ស
២០ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
២១ គណៈកម្មការអ្នកច្បាប់អន្តរជាតិ(ICJ)
២២ សហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស
២៣ ការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ
២៤ Lawyers' Rights Watch Canada (LRWC)
២៥ មាតាធម្មជាតិកម្ពុជា
២៦ Not1More (N1M)
២៧ មជ្ឈមណ្ឌលប្រជាជនដើម្បីការអភិវឌ្ឍនិងសន្តិភាព
២៨ អង្គការតម្លាភាពអន្តរជាតិកម្ពុជា
២៩ អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម
៣០ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន